**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ០៧២
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០
សាលក្រមលេខ ២៨ (ទ)
ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០
ដោយមានសមាសភាព:

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted] ថាណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]។

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទលោក [redacted]។

-អ្នកជំនួយការ គ្មាន។

-អ្នកបកប្រែភាសា គ្មាន។

-សហចុងចម្លើយឈ្មោះ [redacted] សោ ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ និងប្តីឈ្មោះ [redacted] រិៈ អាសយដ្ឋាន [redacted]។

-មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយគ្មាន ។

-អ្នកជំនួយការ គ្មាន។

-អ្នកបកប្រែភាសា គ្មាន។

## អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយសហដើមចោទ:

ក.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] រិៈ និងប្រពន្ធឈ្មោះ [redacted] សោ សងប្រាក់ចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិកឲ្យមកដើមចោទឈ្មោះ [redacted] ថាណាក់ ។

ខ.បង្គាប់ឲ្យសហចុងចម្លើយសងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ចំណាយផ្សេងៗរួមទាំងសេវាកម្មច្បាប់សរុបចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ។

គ.សុំអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទី១ ។

ឃ.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។



Scanned with CamScanner

២.ការពន្យល់ក្រសួងអំពីរឿងក្តី:

ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] វិរៈ និងប្រពន្ធឈ្មោះ [redacted] សោ បានមកទិញដែកពីដើមចោទឈ្មោះ [redacted] ថាណាក់ ជាបន្តបន្ទាប់ ហើយក៏បានទូទាត់ប្រាក់ថ្លៃទិញដែកនេះឲ្យដើមចោទផង ដោយនៅខ្វះប្រាក់ចំនួន ១៧០០.៥ (មួយពាន់ប្រាំពីររយកៀសប្រាំ) ដុល្លាអាមេរិក មិនព្រមធ្វើការទូទាត់សងដើមចោទទេ ។ បន្ទាប់មកនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ សហចុងចម្លើយបានធ្វើកិច្ចសន្យា ដោយយល់ព្រមសងប្រាក់ឲ្យដើមចោទចំនួន ៥០០ (ប្រាំរយ) ដុល្លាអាមេរិក នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩ និងសុំសងរយៈពេល ២ សប្តាហ៍ម្តងៗចំនួន ៥០០ (ប្រាំរយ) ដុល្លាអាមេរិក រហូតសងគ្រប់ចំនួនប្រាក់ដែលជំពាក់ ។ បន្ទាប់ពីចុះកិច្ចសន្យានេះរួចហើយ សហចុងចម្លើយមិនបានអនុវត្តទៅតាម កិច្ចសន្យានោះទេ ហើយចេះតែព្យាយាមគេចវេសពីមួយថ្ងៃទៅមួយថ្ងៃ មិនព្រមសងប្រាក់ឲ្យដើមចោទទេ ។ ទើបដើមចោទដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។

៣.ការអះអាងរបស់ភាគី:

៣/១.លោក [redacted] ជាមេធាវីដើមចោទបានអះអាងថា ៖ ខ្ញុំសូមរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០ ទុកជាបានការដដែល ដោយសារសហចុងចម្លើយពិតជាបានជំពាក់ប្រាក់កូនក្តីរបស់ខ្ញុំដូចការទាមទារក្នុងពាក្យបណ្តឹងពិតប្រាកដមែន តាមរយៈកិច្ចសន្យាចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ រវាងកូនក្តីរបស់ខ្ញុំ និងសហចុងចម្លើយ ។ ហើយសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់របស់ខ្លួនតាមកិច្ចសន្យានោះទេ ។ ជាហេតុធ្វើឲ្យកូនក្តីរបស់ខ្ញុំបាទខាតបង់ប្រាក់ ខាតបង់ពេលវេលា និងបានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់កូនក្តីខ្ញុំយ៉ាងធ្ងន់ធ្ងរ ។ ហើយសូមបដិសេធការអះអាងរបស់សហចុងចម្លើយ និងសូមសំណូមពរឲ្យតុលាការចេញសាលក្រមសម្រេចដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

៣/២.សហចុងចម្លើយឈ្មោះ [redacted] សោ បានថ្លែងការណ៍ក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ៖ នាងខ្ញុំ និងប្តីពិតជាបានចុះកិច្ចសន្យាជំពាក់ប្រាក់ដើមចោទចំនួន ១៧០០ (មួយពាន់ប្រាំពីរ) ដុល្លាអាមេរិក ប្រាកដមែន តែពួកខ្ញុំចុះកិច្ចសន្យានោះ ដោយសារតែពួកខ្ញុំខ្លាច ព្រោះដើមចោទបានគំរាមថានឹងចាប់ពួកខ្ញុំដាក់គុក ហើយនឹងបានយកច្រវ៉ាក់ចាក់ម៉ូតូឃាត់ទុកមិនឲ្យពួកខ្ញុំជិះទៅវិញ ។ ហើយចំពោះប្រាក់ដែលខ្ញុំជំពាក់ដើមចោទនេះ គឺខ្ញុំបានសងបានចំនួន ១១០០ (មួយពាន់មួយរយ) ដុល្លាអាមេរិករួចហើយ ដោយសងជាដំណាក់ៗ ។ ដូចនេះខ្ញុំនៅជំពាក់ប្រាក់តែចំនួន ៦០០ (ប្រាំមួយរយ) ដុល្លាអាមេរិក ។ ក្រោយពេលសងប្រាក់បានចំនួន ១១០០ (មួយពាន់មួយរយ) ដុល្លាអាមេរិក រួចហើយ ប្តីនាងខ្ញុំបានទៅទិញដែកជំពាក់ដើមចោទមួយប៉ុងវិញ តម្លៃប្រហែលជាង ២០០ (ពីររយ) ដុល្លាអាមេរិក ។

៤.ចំណុចវិវាទ៖

-ការទាមទារចុងចម្លើយឈ្មោះ [redacted] វិរៈ និងប្រពន្ធឈ្មោះ [redacted] សោ សងប្រាក់ចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ។

-បង្គាប់ឲ្យសហចុងចម្លើយសងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ចំណាយផ្សេងៗរួមទាំងសេវាកម្មច្បាប់សរុបចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ។



Scanned with CamScanner

៥.ចំណុចគ្មានវិវាទ៖ ពិតជាមានកិច្ចសន្យាជំពាក់ប្រាក់ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ពិតប្រាកដមែន ។

## សំអាងហេតុ

១.ដើមចោទឈ្មោះ[redacted] ថាណាក់ បានដាក់ពាក្យបណ្តឹង និងថ្លែងទាមទារសុំឲ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឲ្យសហចុងចម្លើយឈ្មោះ[redacted]វិរៈ និងប្រពន្ធឈ្មោះ[redacted]សោ ទី១.សងប្រាក់ដើមចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ទី២.សងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងចំណាយផ្សេងៗរួមទាំងសេវាកម្មច្បាប់សរុបចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ទី៣.សូមអនុវត្តជាបណ្តោះអាសន្នចំណុចទី១ និងទី៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។ ដោយដើមចោទអះអាងថាសហចុងចម្លើយបានចុះកិច្ចសន្យាជំពាក់ប្រាក់ខ្លួនចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ។ នៅពេលដល់ថ្ងៃកំណត់ត្រូវសងប្រាក់សហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចនោះទេ ដែលធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ខ្លួនជាច្រើន ។

២.ចុងចម្លើយឈ្មោះ [redacted] សោ បានអះអាងថា ខ្លួន និងប្តីពិតជាបានចុះកិច្ចសន្យាជំពាក់ប្រាក់ដើមចោទចំនួន ១៧០០ (មួយពាន់ប្រាំពីរ) ដុល្លាអាមេរិក ប្រាកដមែន តែពួកខ្លួនចុះកិច្ចសន្យានោះដោយសារតែខ្លាច ព្រោះដើមចោទបានគំរាមថានឹងចាប់ពួកខ្លួនដាក់គុក ហើយនឹងបានយកច្រវាក់ចាក់ម៉ូតូឃាត់ទុកមិនឲ្យពួកខ្លួនជិះទៅវិញ ។ ចំពោះប្រាក់ដែលខ្លួនជំពាក់ដើមចោទនេះ គឺខ្លួនបានសងចំនួន ១១០០ (មួយពាន់មួយរយ) ដុល្លាអាមេរិករួចហើយ ដោយសងជាដំណាក់ៗ ដូចនេះខ្លួននៅជំពាក់ប្រាក់តែចំនួន ៦០០ (ប្រាំមួយរយ) ដុល្លាអាមេរិក ។ ក្រោយពេលសងប្រាក់បានចំនួន ១១០០ (មួយពាន់មួយរយ) ដុល្លាអាមេរិករួចហើយ គឺប្តីរបស់ខ្លួនបានទៅទិញដែកជំពាក់ដើមចោទមួយប៉ុងវិញ តម្លៃប្រហែលជាង ២០០ (ពីររយ) ដុល្លាអាមេរិក ។

៣.តាមការអះអាងរបស់ដើមចោទ ចុងចម្លើយ និងឯកសារកិច្ចសន្យាខ្ចីប្រាក់ ឃើញថាសហចុងចម្លើយឈ្មោះ[redacted]វិរៈ និងប្រពន្ធឈ្មោះ[redacted] សោ ពិតជាបានចុះកិច្ចសន្យាជំពាក់ប្រាក់ដើមចោទឈ្មោះ[redacted] ថាណាក់ ចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិកប្រាកដមែន ។ ដូចនេះតុលាការគប្បីពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ ។

៤.ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចៅក្រមបានកោះហៅសហចុងចម្លើយចូលរួមនីតិវិធី ហើយសហចុងចម្លើយ បានទទួលដីកាកោះរួចហើយ តែអវត្តដោយមិនមានមូលហេតុ ។

៥.ភស្តុតាងជាឯកសារមានៈ កិច្ចសន្យាចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ។

៦.ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១.ទទួលស្គាល់ពាក្យបណ្តឹង និងការទាមទាររបស់ដើមចោទឈ្មោះ[redacted] ថាណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្ន[redacted] ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។

២.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ[redacted]វិរៈ និងប្រពន្ធឈ្មោះ[redacted]សោ ៖



Scanned with CamScanner

២/១.សងប្រាក់ដើមចំនួន ១៧០០ (មួយពាន់ប្រាំពីររយ) ដុល្លាអាមេរិក ឲ្យទៅដើមចោទឈ្មោះ [redacted] ចាណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្ន[redacted]

២/២.សងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងចំណាយផ្សេងៗរួមទាំងសេវាកម្មច្បាប់សរុបចំនួន ៤.០០០.០០០ (បួនលាន) រៀល ឲ្យទៅដើមចោទឈ្មោះ [redacted] ចាណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នផ្ទះលេខ[redacted]

៣.សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបានត្រង់ចំណុច ២/១ ប្រាក់ដើម ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ ។ បើកសិទ្ធិទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner